ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុង

របស់

# គណបក្សសង្គ្រោះជាតិ ( គ.ស.ជ. )

# Internal Regulation

## Cambodia National Rescue Party ( C.N.R.P. )

សង្គ្រោះ បម្រើ ការពារ

កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ

# ជំពូកទី ១
# សមាជិកភាព

**ប្រការ ១ ៖**

លក្ខណសម្បត្តិ ប្រភេទ តួនាទី ភារកិច្ច កាតព្វកិច្ច និងសិទ្ធិអំណាច របស់សមាជិកគណបក្សត្រូវគោរព និង អនុវត្តតាមជំពូកទី២ និងទី៣ នៃលក្ខន្តិកៈគណបក្ស ។

**ប្រការ ២ ៖**

ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ អាចប្រកាសគាំទ្រគណបក្សសង្គ្រោះជាតិបាន ដោយសេរី ។ ការចូលជាសមាជិកសកម្មរបស់គណបក្ស ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ ដែលមានឯកសារ ភ្ជាប់មកជាមួយតាមតម្រូវការ ដើម្បីចុះបញ្ជីក្នុងឯកសារផ្លូវការណាមួយរបស់គណបក្ស ។

**ប្រការ ៣ ៖**

សមាជិកគណបក្ស មានសិទ្ធិចូលរួមផ្ដល់មតិយោបល់ និងមធ្យោបាយដល់គណបក្ស ។ តាមការកោះអញ្ជើញ មកចូលរួមប្រជុំ សមាជិកស្ថាបនិក សមាជិកកិត្តិយស និងសមាជិកសកម្ម មានសិទ្ធិអនុម័ត បោះឆ្នោតជ្រើសតាំងថ្នាក់ ដឹកនាំ ឬសម្រេចកិច្ចការនានារបស់គណបក្សបាន យោងតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស ។

**ប្រការ ៤ ៖**

ថ្នាក់ដឹកនាំគណបក្សត្រូវជ្រើសរើសចេញពីសមាជិកសកម្ម សមាជិកស្ថាបនិក សមាជិកកិត្តិយស ដោយផ្អែក លើលក្ខណសម្បត្តិដូចខាងក្រោមនេះ ៖

១. មានភាពស្មោះត្រង់ និងអនុវត្តតាមគោលការណ៍របស់គណបក្ស

២. មានការតស៊ូ មានការលះបង់ និងមានការទទួលខុសត្រូវខ្ពស់

៣. មានសមត្ថភាព មានលទ្ធភាព ឬបទពិសោធន៍ការងារ

៤. មានសុខភាពល្អ ទាំងផ្លូវកាយ និងផ្លូវចិត្ត

៥. មានគុណធម៌ និងសីលធម៌

**ប្រការ ៥ ៖**

សមាជិកស្ថាបនិក សមាជិកកិត្តិយស និងសមាជិកសកម្មរបស់គណបក្ស អាចសុំលាចេញពីគណបក្សដោយ សេរី ។ ការលុបឈ្មោះចេញពីបញ្ជីគណបក្ស ក្នុងករណីដែលប្រព្រឹត្តល្មើសនឹងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្ស ឬធ្វើសកម្មភាពផ្ទុយនឹងផលប្រយោជន៍គណបក្ស ត្រូវប្រកាសឡើងដោយ ៖

- គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ចំពោះសមាជិកសកម្មនៅតាមភូមិ ឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ នៅក្នុងរាជធានី-ខេត្តសាមី ។

– គណៈកម្មាធិការវិន័យគណបក្ស ចំពោះសមាជិកស្ថាបនិក សមាជិកកិត្តិយស ក្រុមការងាររាជធានី-ខេត្ត គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត និងថ្នាក់ដឹកនាំគណបក្សថ្នាក់ជាតិ ។

នីតិវិធីនៃកិច្ចប្រជុំ និងការធ្វើសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត និងគណៈកម្មាធិការវិន័យគណបក្ស មានចែងនៅក្នុងជំពូកទី២ នៃបទបញ្ញាផ្ទៃក្នុងគណបក្ស ។

## ជំពូកទី ២
## រចនាសម្ព័ន្ធគណបក្ស

**ប្រការ ៦ ៖**

គណបក្សសង្គ្រោះជាតិ មានរចនាសម្ព័ន្ធដូចតទៅ ៖

១. សមាជគណបក្ស

២. ក្រុមប្រឹក្សាជាតិ

៣. គណៈកម្មាធិការនាយក

៤. គណៈកម្មាធិការវិន័យ

៥. គណៈកម្មាធិការប្រតិបត្តិ

៦. គណៈកម្មាធិការអចិន្ត្រៃយ៍

៧. រចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ

## ផ្នែកទី ១
## សមាជគណបក្ស

**ប្រការ ៧ ៖**

សមាជគណបក្ស គឺជាវេទិកាខ្ពស់បំផុតរបស់គណបក្ស ដើម្បីផ្តល់លទ្ធភាពឲ្យសមាជិកគណបក្ស ដែលមានលក្ខណៈជាតំណាង ហើយដែលត្រូវបានអនុញ្ញាតឲ្យចូលរួមសមាជ សម្តែងយោបល់របស់ខ្លួន និងចូលរួមក្នុងការកំណត់ទិសដៅ និងគោលនយោបាយរបស់គណបក្ស ។

សមាជគណបក្សមានពីរប្រភេទ គឺសមាជសាមញ្ញ និងសមាជវិសាមញ្ញ ។ សមាជប្រារព្ធធ្វើឡើងស្របតាមជំពូកទី៥ ផ្នែកទី១ នៃលក្ខន្តិកៈគណបក្ស ។

សមាជសាមញ្ញ ឬវិសាមញ្ញ ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពប្រធានគណបក្ស ។ ក្នុងករណីដែលមិនទាន់មានប្រធានគណបក្ស ឬប្រធានគណបក្សលាលែង សមាជត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាព ប្រធានសមាជមួយរូប ដែលជ្រើសតាំងដោយគណៈកម្មាធិការនាយក ដើម្បីដឹកនាំរៀបចំការបោះឆ្នោតជ្រើសតាំងប្រធានគណបក្ស ។ សមាជលើកទី១ ប្រធានសមាជត្រូវជ្រើសតាំងដោយគណៈកម្មាធិការបណ្តោះអាសន្នរបស់គណបក្ស ។

ប្រធានសមាជមិនមែនជា ៖

- បេក្ខជនប្រធានគណបក្ស
- បេក្ខជនអនុប្រធានគណបក្ស

**ប្រការ ៨ ៖**

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស មានភារកិច្ចកោះប្រជុំ និងរៀបចំសមាជទាំងសាមញ្ញ និងវិសាមញ្ញ ស្របតាមប្រការ២១ និងប្រការ២២ នៃលក្ខន្តិកៈគណបក្ស ។

សមាជិកគណបក្សដែលអាចចូលរួមក្នុងសមាជបាន ៖

- ប្រធាន និងអនុប្រធានគណបក្ស
- គណៈកម្មាធិការនាយក
- គណៈកម្មាធិការប្រតិបត្តិ
- គណៈកម្មាធិការវិន័យ
- ក្រុមប្រឹក្សាជាតិ
- គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត
- គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ
- ប្រធានគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់
- និងសមាជិកសកម្មមួយចំនួនផ្សេងទៀតរបស់គណបក្ស ដែលមានលក្ខណៈជាតំណាង កំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

ការកំណត់សមាសភាព ការអញ្ជើញសមាជិកគណបក្សមកចូលរួមសមាជលើកទី១របស់គណបក្ស រួមទាំងការកំណត់របៀបវារៈ និងទីកន្លែងសមាជ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការបណ្តោះអាសន្នរបស់គណបក្ស ។

**ប្រការ ៩ ៖**

សមាជជ្រើសតាំងប្រធាន និងអនុប្រធានគណបក្ស តាមនីតិវិធីដែលមានចែងក្នុងជំពូកទី៥ ផ្នែកទី៦ ប្រការ៤៤ នៃលក្ខន្តិកៈគណបក្ស ។ ក្នុងករណីមានបញ្ជីបេក្ខជនឈរឈ្មោះជាប្រធាន និងអនុប្រធានគណបក្សតែមួយ នោះសមាជ

បោះឆ្នោតជ្រើសតាំង ប្រធាន និងអនុប្រធានគណបក្ស តាមវិធីលើកដៃ ដោយសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកដែលមានសិទ្ធិសម្រេច ។

អាណត្តិទី១ បេក្ខជនប្រធាន និងអនុប្រធានគណបក្ស គឺជាប្រធាន និងអនុប្រធានចលនាប្រជាធិបតេយ្យសង្គ្រោះជាតិ ។

**ប្រការ ១០ ៖**

សមាជផ្តល់សេចក្តីទុកចិត្តដល់សមាសភាពក្រុមប្រឹក្សាជាតិ តាមរយៈការបោះឆ្នោតដោយលើកដៃ ដោយសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកដែលមានសិទ្ធិសម្រេច ។ ការបោះឆ្នោតនេះធ្វើឡើងបន្ទាប់ពី ប្រធានគណបក្សបង្ហាញបញ្ជីបេក្ខជនឈរឈ្មោះដែលជ្រើសរើសតាមស្មារតីនៃជំពូកទី៥ ផ្នែកទី២ ប្រការ២៣ នៃលក្ខន្តិកៈគណបក្ស ។

**ប្រការ ១១ ៖**

សមាជផ្តល់សេចក្តីទុកចិត្តដល់សមាសភាពគណៈកម្មាធិការនាយក តាមរយៈការបោះឆ្នោតដោយលើកដៃដោយសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកដែលមានសិទ្ធិសម្រេច ។ ការបោះឆ្នោតនេះធ្វើឡើងបន្ទាប់ពីប្រធានគណបក្ស បង្ហាញបញ្ជីបេក្ខជនឈរឈ្មោះដែលជ្រើសរើសតាមស្មារតីនៃជំពូកទី៥ ផ្នែកទី៣ ប្រការ២៥ នៃលក្ខន្តិកៈគណបក្ស ។

ការបោះឆ្នោតដើម្បីអនុម័តសេចក្តីសម្រេចសំខាន់ៗ ដែលគណៈកម្មាធិការនាយក ឬក្រុមប្រឹក្សាជាតិបានដាក់ជូនសមាជ ធ្វើឡើងតាមវិធីលើកដៃ ដោយផ្អែកលើសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកដែលមានសិទ្ធិសម្រេច ។

ការអនុម័ត ឬការធ្វើវិសោធនកម្មលក្ខន្តិកៈគណបក្ស ត្រូវអនុម័តតាមវិធីបោះឆ្នោតដោយលើកដៃ ដោយសម្លេង ២/៣ នៃសមាជិកដែលមានសិទ្ធិសម្រេច ។

## ផ្នែកទី ២
## ក្រុមប្រឹក្សាជាតិ

**ប្រការ ១២ ៖**

ក្រុមប្រឹក្សាជាតិ ដែលជាស្ថាប័នតំណាងសមាជគណបក្ស មានសមាសភាពដូចចែងក្នុងជំពូកទី៥ ផ្នែកទី២ ប្រការ២៣ នៃលក្ខន្តិកៈគណបក្ស ជួបប្រជុំ២ឆ្នាំម្តង ដែលហៅថា សន្និបាតក្រុមប្រឹក្សាជាតិ ។

**ប្រការ ១៣ ៖**

សន្និបាតក្រុមប្រឹក្សាជាតិ ដែលប្រារព្ធឡើងក្រោមអធិបតីភាពប្រធានគណបក្ស ឬប្រធានគណបក្សស្ដីទី តាមការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្ស ដើម្បី ៖

- ធ្វើការពិភាក្សា អនុម័ត ឬផ្ដល់សេចក្ដីទុកចិត្តលើសេចក្ដីសម្រេចនានារបស់គណបក្សដែលដាក់ជូន ដោយគណៈកម្មាធិការនាយក នៅចន្លោះសមាជ
- អនុម័តគោលនយោបាយសំខាន់ៗរបស់គណបក្ស ។

សន្និបាតក្រុមប្រឹក្សាជាតិអាចប្រព្រឹត្តទៅបាន ចាំបាច់ត្រូវមានកូរ៉ុមភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកក្រុមប្រឹក្សាជាតិទាំងមូល ។ សេចក្ដីសម្រេចរបស់សន្និបាតក្រុមប្រឹក្សាជាតិ ត្រូវអនុម័តដោយសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកវត្តមាន ។

**ប្រការ ១៤ ៖**

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ដែលមានភារកិច្ចរៀបចំសន្និបាតក្រុមប្រឹក្សាជាតិ ត្រូវរៀបចំលិខិតអញ្ជើញអ្នកចូលរួមសន្និបាតក្រុមប្រឹក្សាជាតិ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈ ក្នុងរយៈពេល១៥ថ្ងៃយ៉ាងតិចមុនថ្ងៃសន្និបាតក្រុមប្រឹក្សាជាតិ ។

ក្នុងករណីមិនគ្រប់កូរ៉ុម គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ត្រូវរៀបចំលិខិតអញ្ជើញជាលើកទី២ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈ ក្នុងរយៈពេល៧ថ្ងៃយ៉ាងតិច មុនថ្ងៃសន្និបាតក្រុមប្រឹក្សាជាតិ ។ ក្នុងករណីនេះ សន្និបាតក្រុមប្រឹក្សាជាតិនឹងប្រព្រឹត្តទៅដោយមិនគិតកូរ៉ុម ។

សេចក្ដីសម្រេចរបស់សន្និបាតក្រុមប្រឹក្សាជាតិ ត្រូវអនុម័តដោយសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកវត្តមាន ។

## ផ្នែកទី ៣
## គណៈកម្មាធិការនាយក

**ប្រការ ១៥ ៖**

គណៈកម្មាធិការនាយក ដែលជាស្ថាប័ននីតិប្បញ្ញត្តិរបស់គណបក្ស កើតចេញពីសមាជស្របតាមជំពូកទី៥ ផ្នែកទី៣ នៃលក្ខន្តិកៈគណបក្ស មានតួនាទី អនុវត្តទិសដៅ និងគោលនយោបាយរបស់គណបក្ស ដែលសមាជ ឬសន្និបាតក្រុមប្រឹក្សាជាតិបានកំណត់ ។

គណៈកម្មាធិការនាយក ត្រួតពិនិត្យការអនុវត្តន៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការប្រតិបត្តិរបស់គណបក្ស ។

**ប្រការ ១៦ ៖**

សមាជិកគណៈកម្មាធិការនាយកគណបក្ស បាត់បង់សមាជិកភាពរបស់ខ្លួន ដោយ ៖

- មរណភាព ឬ
- ការសុំលាលែង ឬ
- មិនបានចូលរួមប្រជុំគណៈកម្មាធិការនាយកចំនួន ៣ដងជាប់ៗគ្នា ទាំងសាមញ្ញ និងវិសាមញ្ញ ដោយមិនផ្តល់ពីមូលហេតុនៃអវត្តមាន ឬ
- ការលុបឈ្មោះចេញពីបញ្ជីគណបក្ស ។

សមាជិកគណៈកម្មាធិការនាយក ដែលបាត់បង់សមាជិកភាពមានរយៈពេលលើសពី១ឆ្នាំមុនចប់អាណត្តិ ៖

- ករណីសមាជិកមកពីតំណាងគណបក្សរាជធានី-ខេត្ត សមាជិកគណៈកម្មាធិការនាយកថ្មី ត្រូវតែងតាំងចេញពីបញ្ជី បេក្ខជនគណៈកម្មាធិការនាយក តាមលំដាប់លេខរៀងបន្ទាប់នៅក្នុងរាជធានី-ខេត្តសាមី
- ករណីសមាជិកជាសំណើរបស់ប្រធានគណបក្ស សមាជិកគណៈកម្មាធិការនាយកថ្មី ត្រូវជ្រើសរើសដោយគណៈកម្មាធិការនាយក តាមសំណើរបស់ប្រធានគណបក្ស ។

**ប្រការ ១៧ ៖**

គណៈកម្មាធិការនាយក ដែលដឹកនាំដោយប្រធានមួយរូប និងអនុប្រធានយ៉ាងតិចមួយរូប ត្រូវប្រតិបត្តិកិច្ចការរបស់ខ្លួនស្របតាមជំពូកទី៥ ផ្នែកទី៣ នៃលក្ខន្តិកៈគណបក្ស ។

គណៈកម្មាធិការនាយក ត្រូវមានលេខាធិការដ្ឋានមួយ ជាសេនាធិការរបស់ខ្លួន ។ រាល់ការប្រជុំរបស់គណៈកម្មាធិការនាយកត្រូវមានលិខិតអញ្ជើញពីប្រធាន ឬប្រធានស្តីទីរបស់គណៈកម្មាធិការនាយក ជាលាយលក្ខណ៍អក្សរ ឬតាមប្រព័ន្ធអេឡិចត្រូនិក ឬតាមទូរស័ព្ទ ដោយមានបញ្ជាក់នូវកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈ យ៉ាងតិចបីថ្ងៃមុនថ្ងៃប្រជុំ ។

**ប្រការ ១៨ ៖**

រាល់ការផ្តល់សិទ្ធិដល់អនុប្រធានគណៈកម្មាធិការនាយក ឲ្យដឹកនាំការប្រជុំជំនួស ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬដោយចំពោះ ឬតាមប្រព័ន្ធអេឡិកត្រូនិក ពីប្រធានគណៈកម្មាធិការនាយក និងត្រូវជូនដំណឹងទៅប្រធាន និងអនុប្រធានគណបក្ស ។

ករណីអនុប្រធានគណៈកម្មាធិការនាយកអវត្តមាន ប្រធានគណៈកម្មាធិការនាយកអាចផ្តល់សិទ្ធិដល់សមាជិកគណៈកម្មាធិការនាយកមួយរូប ដើម្បីដឹកនាំកិច្ចប្រជុំជំនួស និងត្រូវជូនដំណឹងទៅប្រធាន និងអនុប្រធានគណបក្ស ។

**ប្រការ ១៩ ៖**

សមាជិកចំនួន ១/៤ នៃគណៈកម្មាធិការនាយកមានសិទ្ធិកោះអញ្ជើញ គណៈកម្មាធិការប្រតិបត្តិមកបំភ្លឺពីបញ្ហាអ្វីមួយ ។ ប្រធានគណៈកម្មាធិការប្រតិបត្តិមកបំភ្លឺដោយផ្ទាល់ ឬអាចចាត់តំណាងម្នាក់មកបំភ្លឺបាន ។

**ប្រការ ២០ ៖**

គណៈកម្មាធិការនាយកប្រជុំសាមញ្ញ ៣ខែម្តង ។ ការប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការនាយកអាចធ្វើទៅបានតាមសំណើពីប្រធានគណបក្ស ឬប្រធានគណៈកម្មាធិការនាយក ឬសំណើ ១/៣ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ។

**ប្រការ ២១ ៖**

ការប្រជុំគណៈកម្មាធិការនាយកត្រូវមានកូរ៉ុម ៦/១០ នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ។

ក្នុងករណីដែលមិនគ្រប់កូរ៉ុម ការកោះប្រជុំលើកទីពីរដែលមានរបៀបវារៈដដែល អាចប្រព្រឹត្តទៅបានដោយមិនគិតកូរ៉ុម ។

រាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការនាយក ត្រូវមានសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃចំនួនសមាជិកគណៈកម្មាធិការនាយកទាំងមូល លើកលែងតែសេចក្តីសម្រេចណា ដែលមានចែងក្នុងលក្ខន្តិកៈគណបក្ស ។ សមាជិកគណៈកម្មាធិការនាយកដែលអវត្តមាន ដោយមានការអនុញ្ញាតពីប្រធានគណៈកម្មាធិការនាយកមានសិទ្ធិបោះឆ្នោតតាមរយៈការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនសមាជិកគណៈកម្មាធិការនាយកណាម្នាក់ដែលមានវត្តមាន ។

**ប្រការ ២២ ៖**

សមាជិកគណៈកម្មាធិការនាយក ដែលត្រូវជ្រើសតាំងជាប្រធាន-អនុប្រធានគណៈកម្មាធិការប្រតិបត្តិ អគ្គនាយក-អគ្គនាយករងទាំងបី និងប្រធាន-អនុប្រធានគណៈកម្មាធិការវិន័យ ត្រូវព្យួរតួនាទីជាសមាជិក គណៈកម្មាធិការនាយក ប៉ុន្តែអាចចូលរួមគ្រប់កិច្ចប្រជុំគណៈកម្មាធិការនាយកបាន ដោយមិនគិតកូរ៉ុមប្រជុំ ហើយគ្មានសិទ្ធិបោះឆ្នោតធ្វើសេចក្តីសម្រេច ។

## ផ្នែកទី ៤
## គណៈកម្មាធិការវិន័យ

**ប្រការ ២៣ ៖**

គណៈកម្មាធិការវិន័យ ដែលត្រូវបង្កើតឡើងដោយគណៈកម្មាធិការនាយកស្របតាមប្រការ៣២ នៃលក្ខន្តិកៈគណបក្ស ជាស្ថាប័នទទួលពាក្យបណ្តឹង ដោះស្រាយ ព្រមទាំងដាក់វិន័យ សមាជិកគណបក្ស ដូចមានចែងក្នុងប្រការ៣១ នៃលក្ខន្តិកៈគណបក្ស ។

**ប្រការ ២៤ ៖**

គណៈកម្មាធិការវិន័យ ត្រូវមានលេខាធិការដ្ឋានមួយជាសេនាធិការរបស់ខ្លួន ។ គណៈកម្មាធិការវិន័យ ប្រជុំសាមញ្ញ ៣ខែម្តង ។ ការប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការវិន័យ អាចធ្វើទៅបានដោយមានការស្នើសុំពីប្រធានគណបក្ស ឬសំណើ ១/៣ នៃគណៈកម្មាធិការអចិន្ត្រៃយ៍ ឬប្រធានគណៈកម្មាធិការវិន័យ ឬប្រធានគណៈកម្មាធិការនាយក ពេលមានបញ្ហាណាមួយដែលត្រូវដោះស្រាយ ។

រាល់ការប្រជុំរបស់គណៈកម្មាធិការវិន័យ ត្រូវមានលិខិតអញ្ជើញពីប្រធាន ឬប្រធានស្តីទីរបស់គណៈកម្មាធិការវិន័យ ជាលាយលក្ខណ៍អក្សរ ឬតាមប្រព័ន្ធអេឡិចត្រូនិក ឬតាមទូរស័ព្ទ ដោយមានបញ្ជាក់នូវកាលបរិច្ឆេទ ទីកន្លែង និងរបៀបវារៈ យ៉ាងតិចបីថ្ងៃមុនថ្ងៃប្រជុំ ។

**ប្រការ ២៥ ៖**

រាល់ការផ្តល់សិទ្ធិដល់អនុប្រធានគណៈកម្មាធិការវិន័យ ឲ្យដឹកនាំការប្រជុំជំនួស ត្រូវធ្វើជាលាយលក្ខណ៍ អក្សរ ឬដោយចំពោះ ឬតាមប្រព័ន្ធអេឡិកត្រូនិក ឬតាមទូរស័ព្ទពីប្រធានគណៈកម្មាធិការវិន័យ និងត្រូវជូនដំណឹង ទៅប្រធាន និងអនុប្រធានគណបក្ស ។

ករណីអនុប្រធានគណៈកម្មាធិការវិន័យអវត្តមាន ប្រធានគណៈកម្មាធិការវិន័យ អាចផ្តល់សិទ្ធិដល់សមាជិកគណៈកម្មាធិការវិន័យមួយរូប ដើម្បីដឹកនាំកិច្ចប្រជុំជំនួស និងត្រូវជូនដំណឹងទៅប្រធាន និងអនុប្រធានគណបក្ស ។

**ប្រការ ២៦ ៖**

ការប្រជុំគណៈកម្មាធិការវិន័យត្រូវមានកូរ៉ុម ២/៣ នៃសមាជិកគណៈកម្មាធិការវិន័យទាំងមូល ។

រាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការវិន័យ ត្រូវធ្វើតាមរយៈការបោះឆ្នោតដោយសម្ងាត់ ហើយមានសម្លេងគាំទ្រភាគច្រើនដាច់ខាត (៥០%+១) នៃចំនួនសមាជិកគណៈកម្មាធិការវិន័យទាំងមូល លើកលែងតែសេចក្តីសម្រេចណាដែលមានចែងផ្សេងពីនេះក្នុងលក្ខន្តិកៈ ។

បើប្រជុំលើកទី១មិនគ្រប់កូរ៉ុម ការប្រជុំលើកទីពីរដែលមានរបៀបវារៈដដែល អាចសម្រេចយកជាការបានតាមសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃចំនួនសមាជិកគណៈកម្មាធិការវិន័យទាំងមូល ។

**ប្រការ ២៧ ៖**

សមាជិកគណៈកម្មាធិការវិន័យ ដែលអវត្តមានក្នុងកិច្ចប្រជុំរបស់ខ្លួនចំនួនបីដងជាបន្តបន្ទាប់ ដោយគ្មានការអនុញ្ញាត ត្រូវព្រមានជាលាយលក្ខណ៍អក្សរពីប្រធានគណៈកម្មាធិការវិន័យ ។ បើនៅបន្តអវត្តមានក្នុងកិច្ចប្រជុំ ដោយគ្មានការអនុញ្ញាតចំនួនបីដងជាបន្តបន្ទាប់ទៀត ត្រូវបាត់បង់តួនាទីពីគណៈកម្មាធិការវិន័យដោយស្វ័យប្រវត្តិ ។

ក្នុងករណីនេះប្រធានគណៈកម្មាធិការវិន័យ ត្រូវស្នើសុំមកគណៈកម្មាធិការនាយក ដើម្បីបំពេញបន្ថែមសមាជិកគណៈកម្មាធិការវិន័យ ស្របតាមប្រការ៣២ នៃលក្ខន្តិកៈគណបក្ស ។

**ប្រការ ២៨ ៖**

រាល់វិវាទទាំងអស់អាចប្តឹងចូលមកគណៈកម្មាធិការវិន័យបាន បន្ទាប់ពីការដោះស្រាយតាមរយៈអង្គភាពនីមួយៗ មិនបានសម្រេច ។

ការដោះស្រាយវិវាទត្រូវធ្វើតាមនីតិវិធីដូចតទៅ ៖

- ត្រូវមានពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរពីសមាជិកណាម្នាក់ ប្តឹងទៅគណៈកម្មាធិការវិន័យ ដោយមានបញ្ជាក់នូវហេតុផលភ្ជាប់មកជាមួយនូវភស្តុតាងផ្តិតមេដៃ ឬចុះហត្ថលេខា និងឈ្មោះដើមបណ្តឹង
- ៧ថ្ងៃយ៉ាងយូរបន្ទាប់ពីទទួលពាក្យបណ្តឹង គណៈកម្មាធិការវិន័យត្រូវចាត់វិធានការណ៍ធ្វើការស៊ើបអង្កេត រួមទាំងកោះអញ្ជើញដើមចោទ ចុងចោទ ព្រមទាំងសាក្សី ចូលមកបំភ្លឺ
- ករណីដើមចោទមិនបានចូលខ្លួនតាមការកោះអញ្ជើញលើកទី១ ៧ថ្ងៃក្រោយគណៈកម្មាធិការវិន័យ ត្រូវកោះអញ្ជើញជាលើកទី២ ហើយបើនៅតែមិនចូលមកតាមការកោះអញ្ជើញនេះ ចាត់ទុកសាមីខ្លួនបោះបង់បណ្តឹងរបស់ខ្លួន
- ករណីចុងចោទមិនបានចូលខ្លួនតាមការកោះអញ្ជើញលើកទី១ ៧ថ្ងៃក្រោយគណៈកម្មាធិការវិន័យ ត្រូវកោះអញ្ជើញជាលើកទី២ ហើយបើនៅតែមិនចូលមកតាមការកោះអញ្ជើញនេះ គណៈកម្មាធិការវិន័យអាចធ្វើការពិនិត្យ និងសម្រេចដោយកំបាំងមុខ ។

**ប្រការ ២៩ ៖**

សេចក្តីសម្រេចរបស់គណៈកម្មាធិការវិន័យ ជាសេចក្តីសម្រេចចុងក្រោយ និងបិទផ្លូវតវ៉ា លើកលែងតែការបញ្ចប់សមាជិកភាពថ្នាក់ដឹកនាំគណបក្សថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត ដែលមានចែងក្នុងប្រការ១៧ នៃលក្ខន្តិកៈគណបក្ស ។

## ផ្នែកទី ៥
## គណៈកម្មាធិការប្រតិបត្តិ

**ប្រការ ៣០ ៖**

គណៈកម្មាធិការប្រតិបត្តិ ជាស្ថាប័ននីតិប្រតិបត្តិរបស់គណបក្ស អនុវត្តការងារប្រចាំថ្ងៃមួយផ្នែកធំរបស់គណបក្ស ក្រោមការត្រួតពិនិត្យរបស់ប្រធាន និងអនុប្រធានគណបក្ស ។

ប្រធាន និងអនុប្រធានគណៈកម្មាធិការប្រតិបត្តិ ជ្រើសចេញពីគណៈកម្មាធិការនាយក ស្របតាមប្រការ៣៦ នៃលក្ខន្តិកៈគណបក្ស ។

ប្រធាន អនុប្រធាន អគ្គនាយក និងអគ្គនាយករងទាំងអស់នៃគណៈកម្មាធិការប្រតិបត្តិ ជ្រើសចេញពីសមាជិកគណៈកម្មាធិការនាយក តាមប្រការ៣៦ និងប្រការ៣៧ នៃលក្ខន្តិកៈគណបក្ស ។

ប្រធានគណៈកម្មាធិការប្រតិបត្តិ មានលេខាធិការផ្ទាល់ជាជំនួយ ។

**ប្រការ ៣១ ៖**

ប្រធានគណៈកម្មាធិការប្រតិបត្តិ មានភារកិច្ចដូចតទៅ ៖

- ទំនាក់ទំនងការងារជាមួយគណៈកម្មការនានារបស់គណៈកម្មាធិការនាយក
- រៀបចំ និងអនុវត្តផែនការសកម្មភាពគណបក្ស ស្របតាមគោលការណ៍ ដែលគណៈកម្មាធិការនាយកបានសម្រេច
- រៀបចំគម្រោងថវិការបស់គណបក្ស
- ធ្វើរបាយការណ៍សកម្មភាពរបស់គណបក្ស ប្រចាំឆមាស និងប្រចាំឆ្នាំ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ ស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់គណបក្ស
- ស្នើតែងតាំងថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត និងថ្នាក់ដឹកនាំចលនាមហាជនថ្នាក់ជាតិជូនប្រធានគណបក្ស
- ទំនាក់ទំនងជាមួយអង្គការជាតិ និងអន្តរជាតិ
- គ្រប់គ្រងការងារអគ្គនាយកដ្ឋាន និងសាខាគណបក្សនៅឯនាយសមុទ្រ ។

អនុប្រធានគណៈកម្មាធិការប្រតិបត្តិ ជួយការងារគណបក្ស តាមការកំណត់របស់ប្រធានគណៈកម្មាធិការប្រតិបត្តិ ។ នៅពេលអវត្តមានរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិ អនុប្រធានមួយរូប ត្រូវបានប្រគល់សិទ្ធិដោយប្រធាន ជាប្រធានគណៈកម្មាធិការប្រតិបត្តិស្តីទី ។

ក្នុងករណីអនុប្រធានគណៈកម្មាធិការប្រតិបត្តិអវត្តមាន អ្នកទទួលសិទ្ធិជាប្រធានគណៈកម្មាធិការប្រតិបត្តិស្តីទីត្រូវជ្រើសតាមឋានានុក្រមដូចខាងក្រោម ៖

- អគ្គនាយករដ្ឋបាល
- អគ្គនាយកទំនាក់ទំនងសាធារណៈ
- អគ្គនាយកហិរញ្ញវត្ថុ

**ប្រការ ៣២ ៖**

អគ្គនាយកដ្ឋានរដ្ឋបាល មាននាយកដ្ឋានមួយចំនួនដូចជា ៖

- នាយកដ្ឋានកិច្ចការរដ្ឋបាល
- នាយកដ្ឋានកិច្ចការបោះឆ្នោត និងនីតិកម្ម
- នាយកដ្ឋានអប់រំ និងបណ្តុះបណ្តាល
- នាយកដ្ឋានសង្គមកិច្ច វប្បធម៌ និងសាសនា
- នាយកដ្ឋានព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ

អគ្គនាយករដ្ឋបាល គ្រប់គ្រងសាខាគណបក្សក្រៅប្រទេស និងគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ ។

អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល ជួយការងារតាមការកំណត់របស់អគ្គនាយក ។ នៅពេលអវត្តមាន អគ្គនាយក អគ្គនាយករងមួយរូប ត្រូវបានប្រគល់សិទ្ធិដោយអគ្គនាយក ជាអគ្គនាយកស្តីទី ។

**ប្រការ ៣៣ ៖**

ការរៀបចំ និងការប្រព្រឹត្តិទៅ របស់សាខាគណបក្សនៅក្រៅប្រទេស កំណត់ដោយគណៈកម្មាធិការនាយក តាមសំណើរបស់គណៈកម្មាធិការប្រតិបត្តិ ។ ក្នុងករណីដែលមិនទាន់មានសេចក្តីណែនាំក្នុងការរៀបចំសាខានេះ គណៈកម្មាធិការប្រតិបត្តិ ដែលមានជំនួយពីអគ្គនាយករដ្ឋបាល អាចស្នើសុំប្រធានគណបក្សតែងតាំងសមាសភាពថ្នាក់ដឹកនាំសាខាជាបណ្តោះអាសន្នតាមការចាំបាច់ ។

**ប្រការ ៣៤ ៖**

អគ្គនាយកដ្ឋានទំនាក់ទំនងសាធារណៈ មាននាយកដ្ឋានមួយចំនួនដូចជា ៖

- នាយកដ្ឋានទំនាក់ទំនងកិច្ចការបរទេស
- នាយកដ្ឋានទំនាក់ទំនងអង្គការក្រៅរដ្ឋាភិបាល

អគ្គនាយកទំនាក់ទំនងសាធារណៈ គ្រប់គ្រងចលនាមហាជន លើកលែងក្រុមការងារចលនាយុវជនថ្នាក់ជាតិ ដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ប្រធាន និងអនុប្រធានគណបក្ស ។

អគ្គនាយករងនៃអគ្គនាយកដ្ឋានទំនាក់ទំនងសាធារណៈ ជួយការងារតាមការកំណត់របស់អគ្គនាយក ។ នៅពេលអវត្តមាន អគ្គនាយក អគ្គនាយករងមួយរូប ត្រូវបានប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរដោយអគ្គនាយក ជាអគ្គនាយកស្តីទី ។

**ប្រការ ៣៥ ៖**

ចលនាមហាជនថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានដូចជា ៖

- ចលនាស្ត្រី

- ចលនាយុវជន
- ចលនាកម្មករ
- ចលនាខ្មែរឥស្លាម ...

ថ្នាក់ដឹកនាំចលនាមហាជនថ្នាក់ជាតិ តែងតាំងដោយប្រធានគណបក្ស តាមសំណើរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិ ។

ថ្នាក់ដឹកនាំចលនាមហាជនថ្នាក់ក្រោមជាតិ តែងតាំងដោយប្រធានគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ ។

**ប្រការ ៣៦ ៖**

អគ្គនាយកហិរញ្ញវត្ថុ មានភារកិច្ច ៖

- គ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិទាំងអស់របស់គណបក្ស
- រៀបចំបញ្ជីចំណូល-ចំណាយ
- ធ្វើរបាយការណ៍ចំណូល-ចំណាយរបស់គណបក្ស ប្រចាំខែ និងប្រចាំឆ្នាំ
- រៀបចំលិខិតថ្លែងអំណរគុណជូនដល់សប្បុរសជន ដែលបានធ្វើវិភាគទានជាថវិកា និងទ្រព្យធនផ្សេងៗដល់គណបក្ស
- ស្វែងរកមូលនិធិ ដើម្បីទ្រទ្រង់សកម្មភាពគណបក្ស ។

អគ្គនាយកដ្ឋានហិរញ្ញវត្ថុ មានការិយាល័យមួយចំនួន ជាជំនួយការ ។

**ប្រការ ៣៧ ៖**

អគ្គនាយករងនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុ ជួយការងារតាមការកំណត់របស់អគ្គនាយក ។ នៅពេលអវត្តមានអគ្គនាយក អគ្គនាយករងមួយរូប ត្រូវបានប្រគល់សិទ្ធិដោយអគ្គនាយក ជាអគ្គនាយកស្តីទី ។

**ប្រការ ៣៨ ៖**

គណបក្សត្រូវមានគណនីមួយនៅធនាគារក្នុងរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ។

អ្នកមានសិទ្ធិបើកប្រាក់បាន មានពីររូប គឺប្រធានគណបក្ស ឬអនុប្រធានគណបក្ស និងអគ្គនាយកហិរញ្ញវត្ថុ ឬប្រធានគណបក្ស ឬអនុប្រធានគណបក្ស និងប្រធានគណៈកម្មាធិការប្រតិបត្តិ ឬអគ្គនាយករដ្ឋបាល និងអគ្គនាយកហិរញ្ញវត្ថុ ។

គណបក្សអាចមានគណនីនៅតាមរាជធានី-ខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។

អ្នកមានសិទ្ធិបើកប្រាក់បានមានពីររូប គឺប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត និងហេរញ្ញិករាជធានី-ខេត្ត ។

# ផ្នែកទី ៦
# គណៈកម្មាធិការអចិន្ត្រៃយ៍

**ប្រការ ៣៩ ៖**

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ដឹកនាំ ចាត់ចែង និងអនុវត្តកិច្ចការប្រចាំថ្ងៃរបស់គណបក្ស ស្របតាមជំពូកទី៥ ផ្នែកទី៦នៃលក្ខន្តិកៈគណបក្ស ។

**ប្រការ ៤០ ៖**

នៅក្នុងដំណាក់កាលអន្តរកាល សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវមានការគាំទ្រដោយសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកទាំងមូល បើគ្មានការជំទាស់ពីប្រធាន ឬអនុប្រធានគណបក្ស ស្របតាមប្រការ ៥៥ នៃលក្ខន្តិកៈគណបក្ស ។

**ប្រការ ៤១ ៖**

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស អាចបង្កើតក្រុមការងាររាជធានី-ខេត្ត ដើម្បីជួយការងារគណបក្សតាមរាជធានី-ខេត្ត ។ ចំនួនសមាជិកក្រុមការងាររាជធានី-ខេត្ត យ៉ាងច្រើនស្មើនឹងអាសនៈសភាតាមមណ្ឌល គុណនឹងបួន ។ ខេត្តដែលមានមួយអាសនៈសភា ចំនួនសមាជិកក្រុមការងាររាជធានី-ខេត្តមានយ៉ាងច្រើន៧រូប ។

ប្រធាន អនុប្រធាន និងសមាជិកក្រុមការងាររាជធានី-ខេត្ត តែងតាំងដោយប្រធានគណបក្ស ។

**ប្រការ ៤២ ៖**

ប្រធាន និងអនុប្រធានគណបក្ស មានសេនាធិការមួយចំនួនរួមមាន ៖

- ខុទ្ទកាល័យ
- ក្រុមទីប្រឹក្សា
- ក្រុមការងាររាជធានី-ខេត្ត
- ក្រុមអ្នកតំណាងរាស្ត្រ និងព្រឹទ្ធសភា
- ក្រុមការងារចលនាយុវជនថ្នាក់ជាតិ
- គណៈកម្មការពិសេសមួយចំនួនតាមតម្រូវការចាំបាច់

**ប្រការ ៤៣ ៖**

ខុទ្ទកាល័យមានភារកិច្ច ៖

- តាមដានសភាពការណ៍នយោបាយ សេដ្ឋកិច្ច និងសង្គម ដើម្បីរៀបចំផែនការនយោបាយ សេដ្ឋកិច្ច និងសង្គម ជូនប្រធានគណបក្ស

– រៀបចំឯកសារ និងពិធីការ

– ផ្តល់មតិយោបល់ជុំវិញការដឹកនាំរបស់គណបក្ស ។

**ប្រការ ៤៤ ៖**

ក្រុមអ្នកតំណាងរាស្ត្រ និងព្រឹទ្ធសភា ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយរូប តែងតាំងដោយប្រធានគណបក្ស បន្ទាប់ពីមានការពិគ្រោះយោបល់ពីអ្នកតំណាងរាស្ត្រ និងព្រឹទ្ធសភារបស់គណបក្ស ។

តួនាទី និងភារកិច្ច របស់ក្រុមអ្នកតំណាងរាស្ត្រ និងព្រឹទ្ធសភា កំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

**ប្រការ ៤៥ ៖**

ក្រុមការងារចលនាយុវជនគណបក្សសង្គ្រោះជាតិ ជាតំណាងចលនាយុវជនថ្នាក់ជាតិរបស់គណបក្សសង្គ្រោះជាតិ ដែលមានសមាសភាពដឹកនាំ៥រូប តែងតាំងដោយប្រធានគណបក្ស បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយនឹងអនុប្រធានគណបក្ស ។

តួនាទី និងភារកិច្ច របស់ក្រុមការងារចលនាយុវជនថ្នាក់ជាតិ កំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

**ប្រការ ៤៦ ៖**

គណៈកម្មការពិសេសនីមួយៗ ដែលបង្កើតឡើងតាមតម្រូវការចាំបាច់នោះ ដែលដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយរូប តែងតាំងដោយប្រធានគណបក្ស បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយនឹងអនុប្រធានគណបក្ស ។

តួនាទី និងភារកិច្ច របស់គណៈកម្មការពិសេសនីមួយៗ កំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ។

**ប្រការ ៤៧ ៖**

ក្នុងករណីអនុប្រធានគណបក្ស ត្រូវចាកចេញពីតំណែង ប្រធានគណបក្សមានសិទ្ធិស្នើតែងតាំងអនុប្រធានថ្មីជំនួសបន្ទាប់ពីមានការយល់ព្រមដោយសម្លេងភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិកគណៈកម្មាធិការនាយកទាំងមូល ។ អាណត្តិរបស់អនុប្រធានគណបក្សថ្មីនេះ ត្រូវចប់ជាមួយអាណត្តិរបស់ប្រធានគណបក្ស ។

## ផ្នែកទី៧
## រចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ

**ប្រការ ៤៨ ៖**

រចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ ត្រូវរៀបចំជាតំណាងគណបក្សភូមិ គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ និងគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ។

**ប្រការ ៤៩ ៖**

សមាសភាពគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ រួមមាន ៖

- ថ្នាក់ដឹកនាំគណបក្សភូមិ (ប្រធានមួយរូប អនុប្រធានមួយរូប និងជំនួយការមួយរូប)
- ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ (ប្រធានមួយរូប អនុប្រធានពីររូប លេខាធិការមួយរូប និងហេរញ្ញិកមួយរូប)
- ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ (ប្រធានមួយរូប អនុប្រធានពីររូប លេខាធិការមួយរូប និងហេរញ្ញិកមួយរូប)
- ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត (ប្រធានមួយរូប អនុប្រធានពីររូប លេខាធិការមួយរូប និងហេរញ្ញិកមួយរូប)

**ប្រការ ៥០ ៖**

តំណាងគណបក្សភូមិនីមួយៗ មានសមាជិកសកម្មយ៉ាងតិច៣រូប រស់នៅក្នុងភូមិសាមី ដែលបានស្ម័គ្រចិត្តដាក់ពាក្យសុំចូលជាសមាជិកគណបក្សសង្គ្រោះជាតិ ។ ថ្នាក់ដឹកនាំគណបក្សភូមិ តែងតាំងដោយប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត តាមសំណើរបស់គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ សម្រាប់អាណត្តិ ៥ឆ្នាំ ។

តំណាងគណបក្សភូមិនីមួយៗ មានភារកិច្ច ៖

- អនុវត្ត និងផ្សព្វផ្សាយគោលនយោបាយ កម្មវិធីនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស ដល់ប្រជាពលរដ្ឋនៅក្នុងភូមិសាមី
- រាយការណ៍ជូនថ្នាក់ដឹកនាំគណបក្ស អំពីសភាពការណ៍សង្គម សេដ្ឋកិច្ច និងនយោបាយទូទៅដែលកើតមាននៅក្នុងភូមិ ។

**ប្រការ ៥១ ៖**

ថ្នាក់ដឹកនាំគណបក្សភូមិនីមួយៗ និងប្រធានចលនាមហាជនឃុំ-សង្កាត់ (យុវជន ស្ត្រី...) មានសិទ្ធិបោះឆ្នោត និងឈរឈ្មោះជាបេក្ខជនគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់សាមី ។

ថ្នាក់ដឹកនាំគណបក្សភូមិនីមួយៗ ដែលជាប់ឆ្នោតជាថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ ត្រូវលាលែងពីថ្នាក់ដឹកនាំគណបក្សភូមិ ។ ក្នុងករណីនេះ ប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ត្រូវតែងតាំងឡើងវិញនូវថ្នាក់ដឹកនាំគណបក្សភូមិសាមី ។

**ប្រការ ៥២ ៖**

គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ មានចំនួនយ៉ាងច្រើនស្មើនឹងអាសនៈក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលកំណត់ដោយរាជរដ្ឋាភិបាល បូកនឹងចំនួនភូមិក្នុងឃុំ-សង្កាត់សាមី ។

គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់នីមួយៗ ជ្រើសតាំងតាមរយៈការបោះឆ្នោតសម្ងាត់ និងដោយសម្លេងប្រៀប សម្រាប់អាណត្តិ ៥ឆ្នាំ ជ្រើសរើសចេញពីបេក្ខជនដែលទទួលបានសម្លេងឆ្នោតគាំទ្រច្រើនបន្តបន្ទាប់ និងតែងតាំងដោយអគ្គនាយករដ្ឋបាលគណបក្ស តាមសំណើរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ។

**ប្រការ ៥៣ ៖**

គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ មានតួនាទី និងភារកិច្ច ៖

- ធានាដំណើរការគណបក្សនៅក្នុងឃុំ-សង្កាត់សាមី
- អនុវត្ត និងផ្សព្វផ្សាយគោលនយោបាយ កម្មវិធីនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស ដល់ប្រជាពលរដ្ឋនៅក្នុងឃុំ-សង្កាត់សាមី
- ធ្វើរបាយការណ៍ប្រចាំខែស្តីអំពីសកម្មភាពការងាររបស់ខ្លួន និងអំពីសភាពការណ៍សង្គម សេដ្ឋកិច្ច និងនយោបាយទូទៅ ដែលកើតមាននៅក្នុងឃុំ-សង្កាត់ ជូនគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ ។

**ប្រការ ៥៤ ៖**

ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ ប្រធានចលនាមហាជនឃុំ-សង្កាត់ មានសិទ្ធិបោះឆ្នោត និងឈរឈ្មោះជាបេក្ខជនគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ ។ ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់នីមួយៗ ដែលជាប់ឆ្នោតជាថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ ត្រូវលាលែងពីថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ ។ ក្នុងករណីនេះ អគ្គនាយករដ្ឋបាលគណបក្ស ត្រូវតែងតាំងឡើងវិញនូវថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ តាមសម្លេងឆ្នោតគាំទ្រជាបន្តបន្ទាប់នាពេលបោះឆ្នោតជ្រើសរើស ។

ប្រធានគណបក្សភូមិ ជាសមាជិកគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់សាមី ដោយស្វ័យប្រវត្តិ ។

**ប្រការ ៥៥ ៖**

គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ មានចំនួនយ៉ាងច្រើនស្មើនឹងអាសនៈក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ ដែលកំណត់ដោយរាជរដ្ឋាភិបាល បូកនឹងចំនួនឃុំ-សង្កាត់ ក្នុងក្រុង-ស្រុក-ខណ្ឌសាមី ។

គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌនីមួយៗ ជ្រើសតាំងតាមរយៈការបោះឆ្នោតសម្ងាត់ និងដោយសម្លេងប្រៀប សម្រាប់អាណត្តិ ៥ឆ្នាំ ជ្រើសរើសចេញពីបេក្ខជនដែលទទួលបានសម្លេងឆ្នោតគាំទ្រច្រើនបន្តបន្ទាប់ និងតែងតាំងដោយប្រធានគណៈកម្មាធិការប្រតិបត្តិគណបក្ស តាមសំណើរបស់អគ្គនាយករដ្ឋបាលគណបក្ស ។

ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌនីមួយៗ ដែលជាប់ឆ្នោតជាថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ត្រូវលាលែងពីថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ ។ ក្នុងករណីនេះ ប្រធានគណៈកម្មាធិការប្រតិបត្តិគណបក្ស ត្រូវតែងតាំងឡើងវិញនូវថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ តាមសម្លេងឆ្នោតគាំទ្រជាបន្តបន្ទាប់នៅពេលបោះឆ្នោតជ្រើសរើស ។

ប្រធានគណបក្សឃុំ-សង្កាត់ ជាសមាជិកគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌសាមី ដោយស្វ័យប្រវត្តិ ។

**ប្រការ ៥៦ ៖**

គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ មានតួនាទី និងភារកិច្ច ៖

- ជានាដំណើរការគណបក្សនៅក្នុងក្រុង-ស្រុក-ខណ្ឌសាមី
- អនុវត្ត និងផ្សព្វផ្សាយគោលនយោបាយ កម្មវិធីនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស ដល់ប្រជាពលរដ្ឋនៅក្នុងក្រុង-ស្រុក-ខណ្ឌសាមី
- ធ្វើរបាយការណ៍ប្រចាំខែស្តីអំពីសកម្មភាពការងាររបស់ខ្លួន និងអំពីសភាពការណ៍សង្គម សេដ្ឋកិច្ច និងនយោបាយទូទៅដែលកើតមាននៅក្នុងក្រុង-ស្រុក-ខណ្ឌជូនគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ។

**ប្រការ ៥៧ ៖**

ថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ ប្រធានចលនាមហាជនក្រុង-ស្រុក-ខណ្ឌ មានសិទ្ធិបោះឆ្នោត និងឈរឈ្មោះជាបេក្ខជនគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ។

**ប្រការ ៥៨ ៖**

គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត មានចំនួនយ៉ាងច្រើនស្មើនឹងអាសនៈក្រុមប្រឹក្សារាជធានី-ខេត្ត ដែលកំណត់ដោយរាជរដ្ឋាភិបាល បូកនឹងចំនួនក្រុង-ស្រុក-ខណ្ឌ ក្នុងរាជធានី-ខេត្តសាមី ។

គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្តនីមួយៗ ជ្រើសតាំងតាមរយៈការបោះឆ្នោតសម្ងាត់ និងដោយសម្លេងប្រៀប សម្រាប់អាណត្តិ ៥ឆ្នាំ ជ្រើសរើសចេញពីបេក្ខជនដែលទទួលបានសម្លេងឆ្នោតគាំទ្រច្រើនបន្តបន្ទាប់ តែងតាំងដោយប្រធានគណបក្ស តាមសំណើរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិគណបក្ស ។

ប្រធានគណបក្សក្រុង-ស្រុក-ខណ្ឌ ជាសមាជិកគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្តសាមី ដោយស្វ័យប្រវត្តិ ។

**ប្រការ ៥៩ ៖**

គណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត មានតួនាទី និងភារកិច្ច ៖

- ជានាដំណើរការគណបក្សនៅក្នុងរាជធានី-ខេត្តសាមី
- អនុវត្ត និងផ្សព្វផ្សាយគោលនយោបាយ កម្មវិធីនយោបាយ សេចក្តីសម្រេចនានារបស់គណបក្ស ដល់ប្រជាពលរដ្ឋនៅក្នុងរាជធានី-ខេត្តសាមី
- សហការការងារជាមួយក្រុមការងាររាជធានី-ខេត្តសាមី
- ធ្វើរបាយការណ៍ប្រចាំខែស្តីអំពីសកម្មភាពការងាររបស់ខ្លួន និងអំពីសភាពការណ៍សង្គម សេដ្ឋកិច្ច និងនយោបាយទូទៅដែលកើតមាននៅក្នុងរាជធានី-ខេត្ត ជូនអគ្គនាយករដ្ឋបាល ។
- អនុវត្តប្រការ១៧ នៃលក្ខន្តិកៈគណបក្ស ។

**ប្រការ ៦០ ៖**

គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត ប្រជុំយ៉ាងតិចមួយខែម្តង ។ រាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត ចាំបាច់ត្រូវមានសម្លេងគាំទ្រភាគច្រើនដាច់ខាត (៥០%+១) លើកូរ៉ុម ៦/១០ នៃគណៈកម្មាធិការប្រតិបត្តិឃុំ-សង្កាត់ ក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត ទាំងមូល ។

**ប្រការ ៦១ ៖**

គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត អាចស្នើសុំតែងតាំងទីប្រឹក្សារបស់ខ្លួនយ៉ាងច្រើន ១/៣ នៃអាសនៈក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត ដែលកំណត់ដោយរាជរដ្ឋាភិបាល ។

ទីប្រឹក្សារបស់គណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្ត តែងតាំងដោយប្រធានគណៈកម្មាធិការប្រតិបត្តិក្រុង-ស្រុក-ខណ្ឌ និងរាជធានី-ខេត្តសាមី ។

**ប្រការ ៦២ ៖**

នីតិវិធិ និងបែបបទ រៀបចំការបោះឆ្នោតជ្រើសតាំងរចនាសម្ព័ន្ធគណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ កំណត់ដោយសេចក្តីណែនាំរបស់អគ្គនាយករដ្ឋបាលគណបក្ស ។

## ជំពូកទី ៣
## ធនធាន និងថវិកា

**ប្រការ ៦៣ ៖**

ធនធាន និងថវិការបស់គណបក្ស បានមកពីភាគទានរបស់សមាជិក ។ ការបង់ភាគទានជូនគណបក្ស ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

- សមាជិករដ្ឋសភា និងព្រឹទ្ធសភា ត្រូវបង់ចំនួន ១២% នៃប្រាក់បំណាច់ប្រចាំខែ
- សមាជិកក្រុមការងាររាជធានី-ខេត្ត ត្រូវបង់យ៉ាងតិចចំនួន ៤ម៉ឺនរៀល ប្រចាំខែ
- សមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត ត្រូវបង់ចំនួន ១០% នៃប្រាក់បំណាច់ប្រចាំខែ
- សមាជិកក្រុមប្រឹក្សាក្រុង-ស្រុក-ខណ្ឌ ត្រូវបង់ចំនួន ១០% នៃប្រាក់បំណាច់ប្រចាំខែ
- គណៈកម្មាធិការទាំងបី ត្រូវបង់ចំនួន ៥ម៉ឺនរៀល ប្រចាំខែ ។

គណៈកម្មាធិការប្រតិបត្តិថ្នាក់ក្រោមជាតិ ដែលមិនស្ថិតនៅក្នុងតំណែង ជាសមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ អាចបង់ភាគទានប្រចាំខែតាមការស្ម័គ្រចិត្ត ។

**ប្រការ ៦៤ ៖**

ភាគទានប្រចាំខែរបស់សមាជិករដ្ឋសភា ព្រឹទ្ធសភា និងគណៈកម្មាធិការទាំងបី រួមទាំងវិភាគទានរបស់សប្បុរជននានា ត្រូវបង់ចូលក្នុងគណនីគណបក្សថ្នាក់ជាតិ ។

ភាគទានប្រចាំខែរបស់ក្រុមការងាររាជធានី-ខេត្ត សមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ រួមទាំងវិភាគទាន របស់សប្បុរជននានាក្នុងរាជធានី-ខេត្ត ត្រូវរក្សាទុកសម្រាប់ដំណើរការ ការងារគណបក្សក្នុងរាជធានី-ខេត្តសាមី ។

**ប្រការ ៦៥ ៖**

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស អាចកំណត់ការបង់ភាគទានបន្ថយ ឬបន្ថែម ដល់ថ្នាក់ដឹកនាំគណបក្សដែលជាប់កាតព្វកិច្ចទាំងអស់ក្នុងករណីចាំបាច់ ។

**ប្រការ ៦៦ ៖**

ថ្នាក់ដឹកនាំគណបក្សគ្រប់លំដាប់ថ្នាក់ ដែលមិនអនុវត្តនូវកាតព្វកិច្ចដូចចែងក្នុងប្រការ៦១ខាងលើ ត្រូវចាត់វិធានការដូចខាងក្រោម ៖

ចំពោះថ្នាក់ដឹកនាំគណបក្សថ្នាក់ជាតិ ៖

- បើមិនបង់ភាគទានចំនួនពីរខែបន្តបន្ទាប់ អគ្គនាយកហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់សាមីខ្លួន ដោយតម្រូវឲ្យបង់ភាគទានទាំងពីរខែនោះក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីការជូនដំណឹង
- បើនៅតែមិនបង់ភាគទានចំនួនពីរខែបន្តបន្ទាប់ទៀត អគ្គនាយកហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សាមីខ្លួន ដោយតម្រូវឲ្យបង់ភាគទានទាំងបួនខែនោះក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីការជូនដំណឹង
- បើសាមីខ្លួននៅតែមិនបង់ភាគទានជូនគណបក្ស អគ្គនាយកហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ទៅគណៈកម្មាធិការវិន័យ ដើម្បីដោះស្រាយ និងដាក់វិន័យ ។

ចំពោះក្រុមការងាររាជធានី-ខេត្ត ៖

- បើមិនបង់ភាគទានចំនួនពីរខែបន្តបន្ទាប់ ប្រធានក្រុមការងារត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់សាមីខ្លួន ដោយតម្រូវឲ្យបង់ភាគទានទាំងពីរខែនោះក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីការជូនដំណឹង
- បើនៅតែមិនបង់ភាគទានចំនួនពីរខែបន្តបន្ទាប់ទៀត ប្រធានក្រុមការងារត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សាមីខ្លួន ដោយតម្រូវឲ្យបង់ភាគទានទាំងបួនខែនោះក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីការជូនដំណឹង
- បើសាមីខ្លួននៅតែមិនបង់ភាគទានជូនគណបក្ស ប្រធានក្រុមការងារត្រូវកោះប្រជុំក្រុមការងាររាជធានី-ខេត្ត ដើម្បីដោះស្រាយ និងដាក់វិន័យ ។

ចំពោះថ្នាក់ដឹកនាំគណបក្សថ្នាក់ក្រោមជាតិ ៖

- បើមិនបង់ភាគទានចំនួនពីរខែបន្តបន្ទាប់ ប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សាមីខ្លួន ដោយតម្រូវឲ្យបង់ភាគទានទាំងពីរខែនោះក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីការជូនដំណឹង
- បើនៅតែមិនបង់ភាគទានចំនួនពីរខែបន្តបន្ទាប់ទៀត ប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់សាមីខ្លួន ដោយតម្រូវឲ្យបង់ភាគទានទាំងបួនខែនោះក្នុងរយៈពេល៧ថ្ងៃបន្ទាប់ពីការជូនដំណឹង
- បើសាមីខ្លួននៅតែមិនបង់ភាគទានជូនគណបក្ស ប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ត្រូវកោះប្រជុំគណៈកម្មាធិការប្រតិបត្តិរាជធានី-ខេត្ត ដើម្បីដោះស្រាយ និងដាក់វិន័យ ។

គណៈកម្មាធិការវិន័យ ដោយសហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាល និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុ មានភារកិច្ចរៀបចំបែបបទ និងនីតិវិធីសម្រាប់ការដាក់វិន័យចំពោះសមាជិកគណបក្ស ដែលមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងប្រការ៦១ នៃបទបញ្ជាផ្ទៃក្នុងគណបក្ស ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**ប្រការ ៦៧ ៖**

ក្នុងអំឡុងអន្តរកាល ការដឹកនាំគណបក្ស ត្រូវស្របនឹងខ្លឹមសារដែលមានចែងក្នុងអន្តរប្បញ្ញត្តិនៃលក្ខន្តិកៈគណបក្ស ។

**ប្រការ ៦៨ ៖**

ការធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់គណបក្ស ជាសមត្ថកិច្ចរបស់គណៈកម្មាធិការនាយក តាមសំណើរបស់ប្រធានគណបក្ស ឬប្រធានគណៈកម្មាធិការនាយក ឬមតិ ១/៣ នៃគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ឬមតិ ១/៣ នៃសមាជិកគណៈកម្មាធិការនាយក ។

**ប្រការ ៦៩ ៖**

បទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានារបស់គណបក្សត្រូវស្របនឹងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់គណបក្សជាដាច់ខាត ។

**ប្រការ ៧០ ៖**

បទបញ្ជាផ្ទៃក្នុងនេះអនុម័ត ត្រូវបានវិសោធនកម្មដោយគណៈកម្មាធិការនាយក ក្នុងកិច្ចប្រជុំថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណបក្ស ។

អនុម័ត ថ្ងៃទី.................... ខែ............................ ឆ្នាំ....................

រាជធានីភ្នំពេញ ថ្ងៃទី.................... ខែ............................ ឆ្នាំ....................

**ជ.គណៈកម្មាធិការនាយក**

**ប្រធាន**

**ប៉ុល ហំម**

បានឃើញ និងឯកភាព

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី............... ខែ........................ ឆ្នាំ....................

**ប្រធានគណបក្ស**

**សម រង្ស៊ី**